# ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៧៨

# ស្តីពី

# លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ

# មន្ត្រីនគរបាលជាតិកម្ពុជា

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០០១

## ក្រោសមបន្ទាន់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មន្ត្រីនគរបាលជាតិទាំងអស់ត្រូវស្ថិតនៅក្នុងបទប្បញ្ញតិរបស់លក្ខន្តិកៈដោយឡែកនេះ ។

**មាត្រា២ .-**

មន្ត្រីនគរបាលជាតិកម្ពុជាមានភារកិច្ចថែរក្សា ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងស្ថេរភាពសង្គម ដើម្បីបំរើផលប្រយោជន៍របស់ប្រទេសជាតិ និងប្រជាពលរដ្ឋ ។

មន្ត្រីនគរបាលជាតិកម្ពុជាត្រូវគោរពវិន័យយ៉ាងម៉ឹងម៉ាត់ មានភក្តីភាពចំពោះជាតិ សាសនា ព្រះមហាក្សត្រ និងអង់អាចក្លាហាន ហ៊ានធ្វើពលីកម្មនៅគ្រប់កាលៈទេសៈទាំងអស់ចំពោះមាតុភូមិ ។

លក្ខន្តិកៈដោយឡែកនេះធានាសិទ្ធិ កាតព្វកិច្ច និងផលប្រយោជន៍ចំពោះមន្ត្រីនគរបាលជាតិកម្ពុជាគ្រប់រូប ។

**មាត្រា៣ .-**

ឋានានុក្រមរបស់នគរបាលជាតិកម្ពុជា រួមមាន ០៤ ប្រភេទ :

១-នាយនគរបាលថ្នាក់ឧត្តមសេនីយ៍

២-នាយនគរបាលជាន់ខ្ពស់

៣-នាយនគរបាល

៤-នាយនគរបាលរង

**មាត្រា៤ .-**

លំដាប់ថ្នាក់ឋានន្តរសក្តិនគរបាលជាតិកម្ពុជាមាន :

១-ឋានន្តរសក្តិនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ :

-នាយឧត្តមសេនីយ៍

-ឧត្តមសេនីយ៍ឯក

-ឧត្តមសេនីយ៍ទោ

-ឧត្តមសេនីយ៍ត្រី

២-ឋានន្តរសក្តិនាយនគរបាលជាន់ខ្ពស់ :

-វរសេនីយ៍ឯក

-វរសេនីយ៍ទោ

-វរសេនីយ៍ត្រី

៣-ឋានន្តរសក្តិនាយនគរបាល :

-អនុសេនីយ៍ឯក

-អនុសេនីយ៍ទោ

-អនុសេនីយ៍ត្រី

-នាយចំណង់

៤-ឋានន្តសក្តិនាយនគរបាលរង :

-ព្រិន្ទបាលឯក

-ព្រិន្ទបាលទោ

-ពលបាលឯក

-ពលបាលទោ

-ពលបាលត្រី

**មាត្រា៥ .-**

ការតែងតាំង ការតម្លើងថ្នាក់ ការតម្លើងឋានន្តរសក្តិ ការផ្លាស់ប្តូរ ត្រូវសំរេចដោយ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសេចក្តីសំរេច ។

ការបញ្ឈប់លែងអោយធ្វើការដោយបង្ខំ ការដាក់អោយចូលនិវត្តន៍មុនកំណត់ និងការដកហូតមុខតំណែងត្រូវសំរេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសេចក្តីសំរេច ។

## ជំពូកទី ២

## ការជ្រើសរើសអោយចូលធ្វើការ

**មាត្រា៦ .-**

ការជ្រើសរើសអោយចូលធ្វើការក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ត្រូវធ្វើតាមរយៈ ការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត ឬ និងក្នុងចំណោមមន្ត្រីរាជការដែលមានក្របខ័ណ្ឌ ។ ចំនួន

នៃកន្លែងដែលត្រូវផ្ដល់ក្នុងការប្រឡងប្រជែងសំរាប់សិស្ស និងនិស្សិត ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៧ .-**

ការប្រឡងជ្រើសរើសអោយចូលជានាយនគរបាល ត្រូវធ្វើចំពោះបេក្ខជនជាសិស្ស និស្សិតទាំងពីរប្រភេទដែលមានសញ្ញាប័ត្របរិញ្ញា ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ និងមានអាយុយ៉ាងច្រើន ៣០ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។ បើជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌ បេក្ខជនត្រូវមានសញ្ញាប័ត្របរិញ្ញា ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ និងមានអាយុយ៉ាងច្រើនបំផុត ៣៥ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។

**មាត្រា៨ .-**

ការប្រឡងជ្រើសរើសអោយចូលជានាយនគរបាលរង ត្រូវធ្វើចំពោះបេក្ខជនជាសិស្ស និស្សិតទាំងពីរប្រភេទដែលមានសញ្ញាប័ត្រយ៉ាងទាបបំផុត មធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រដែលមានតំលៃស្មើ និងមានអាយុយ៉ាងច្រើន ២៥ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។ បើជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌ បេក្ខជនត្រូវមានសញ្ញាប័ត្រយ៉ាងទាបបំផុតមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ និងមានអាយុយ៉ាងច្រើនបំផុត ៣០ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។

**មាត្រា៩ .-**

បេក្ខជនទាំងពីរភេទដែលត្រូវបានប្រឡងជាប់ ជាសិស្សនាយនគរបាល និងជាសិស្ស នាយនគរ-បាលរងត្រូវបានទទួលការបណ្ដុះបណ្ដាលជាដំបូង ដោយក្រសួងមហាផ្ទៃ ។ រយៈពេលបណ្ដុះបណ្ដាលនេះ នឹងចាត់ទុកជារយៈពេលកម្មសិក្សារបស់សិស្សនាយនគរបាល និងសិស្សនាយនគរបាលរងទាំងនោះ ។

**មាត្រា១០ .-**

ក្រោយការបណ្ដុះបណ្ដាលសិស្សនាយនគរបាល និងសិស្សនាយនគរបាលរងត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ។ សិស្សនាយនគរបាលត្រូវបានតែងតាំងឋានន្តរសក្ដិជានាយចំណង់ និងសិស្សនាយនគរបាលរង ត្រូវបានតែងតាំងឋានន្តរសក្ដិជាពលបាលត្រី ។

## ជំពូកទី ៣
## បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ

**មាត្រា១១ .-**

មន្ត្រីនគរបាលជាតិកម្ពុជាមានសិទ្ធិទទួលប្រាក់បៀវត្សដែលចំនួនទឹកប្រាក់ កំណត់ទៅតាមឋានន្តរសក្ដិ ។

មន្ត្រីនគរបាលជាតិកម្ពុជា អាចទទួលប្រាក់បន្ថែមបំណាច់ពិសេស ផ្តល់ជូនទៅតាមប្រភេទមុខងារតំណែងដែលខ្លួនបានបំពេញ ។

ប្រាក់បៀវត្ស ប្រាក់បំណាច់ពិសេស និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត នឹងត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

**មាត្រា១២ .-**

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវបានទទួលរបបនៃការឈប់ប្រចាំឆ្នាំ ការឈប់សំរាកព្យាបាលជម្ងឺ និងឈប់សំរាកផ្សេងៗទៀតដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤

## ការតម្លើងឋានន្តរសក្តិ

**មាត្រា១៣ .-**

ការតម្លើងឋានន្តរសក្តិរបស់មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវគិតទៅលើលក្ខណៈសម្បត្តិ និងអតីតភាពការងារកន្លងមក ។

**មាត្រា១៤ .-**

លក្ខណៈសម្បត្តិសំរាប់ពិនិត្យក្នុងការស្នើតម្លើងឋានន្តរសក្តិ ត្រូវផ្អែកតាមព្រឹត្តិប័ត្រពិន្ទុមន្ត្រីនគរបាលជាតិកម្ពុជា ដូចមានកំណត់ខាងក្រោម :

១-ការគោរពវិន័យ

២-ការចាត់តាំង

៣-កិរិយាមាយាទ និងសីលធម៌

៤-សមត្ថភាពបំពេញភារកិច្ច

[illegible]ការងារ

[illegible]ភាព

៧-[illegible]បរទេស [illegible]បារាំង ឬអង់គ្លេស)

**មាត្រា១៥ ._**

ការតម្លើងឋានន្តរសក្តិរបស់មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវអនុវត្តទៅតាមវេនជ្រើសរើស ។ ប៉ុន្តែមិនអាចអនុវត្តបានប្រសិនបើមន្ត្រីនគរបាលជាតិកម្ពុជាណាបំរើការងារមិនគ្រប់តាមល័ក្ខខ័ណ្ឌ និងរយៈពេលកំណត់ ។ រយៈពេលដែលត្រូវតម្លើងឋានន្តរសក្តិដូចខាងក្រោម :

**ក_នាយនគរបាលរង :**

| ឋានន្តរសក្តិ | រយៈពេលបំរើការងារក្នុងឋានន្តរសក្តិមួយថ្នាក់ដើម្បីអាចតម្លើងបាន |
|---|---|
| ពលបាលត្រី | ២ ឆ្នាំ |
| ពលបាលទោ | ២ ឆ្នាំ |
| ពលបាលឯក | ២ ឆ្នាំ |
| ព្រិន្ទបាលទោ | ២ ឆ្នាំ |
| ព្រិន្ទបាលឯក | ២ ឆ្នាំ |

*ចំពោះនាយនគរបាលរងថ្នាក់ព្រិន្ទបាលឯក ដែលមានអតីតភាព ២ ឆ្នាំឡើង មានសិទិប្រឡងជ្រើសរើស និងទទួលការបណ្តុះបណ្តាលបន្ថែមជានាយនគរបាលតាមការកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ និងតាមតម្រូវការចាំបាច់របស់នគរបាលជាតិកម្ពុជា ។

**ខ_នាយនគរបាល :**

| ឋានន្តរសក្តិ | រយៈពេលបំរើការងារក្នុងឋានន្តរសក្តិមួយថ្នាក់ដើម្បីអាចតម្លើងបាន |
|---|---|
| នាយចំណង់ | ១ ឆ្នាំ |
| អនុសេនីយ៍ត្រី | ២ ឆ្នាំ |
| អនុសេនីយ៍ទោ | ៣ ឆ្នាំ |
| អនុសេនីយ៍ឯក | ៣ ឆ្នាំ |

*ចំពោះនាយនគរបាលថ្នាក់អនុសេនីយ៍ឯក ដែលមានអតីតភាព ៣ ឆ្នាំឡើង មានសិទ្ធិប្រឡងជ្រើសរើស និងទទួលការបណ្តុះបណ្តាលបន្ថែមជានាយនគរបាលជាន់ខ្ពស់បាន តាមការកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ និងតាមតម្រូវការចាំបាច់របស់នគរបាលជាតិកម្ពុជា ។

**គ-នាយនគរបាលជាន់ខ្ពស់ :**

| ឋានន្តរសក្តិ | រយៈពេលបំរើការងារក្នុងឋានន្តរសក្តិមួយថ្នាក់ដើម្បីអាចតម្លើងបាន |
|---|---|
| វរសេនីយ៍ត្រី | ៥ ឆ្នាំ |
| វរសេនីយ៍ទោ | ៥ ឆ្នាំ |
| វរសេនីយ៍ឯក | ៦ ឆ្នាំ |

*ចំពោះនាយនគរបាលជាន់ខ្ពស់ថ្នាក់វរសេនីយ៍ឯក ដែលមានអតីតភាព ៦ ឆ្នាំឡើង ទើបអាចធ្វើសំណើតែងតាំងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ ដោយយោងទៅតាមតម្រូវការចាំបាច់របស់ប្រទេសជាតិ ។

ចំពោះមន្ត្រីនគរបាលជាតិកម្ពុជាដែលពលី ត្រូវបានតម្លើង ឋានន្តរសក្តិមួយថ្នាក់ជាកិច្ចបច្ឆាមរណៈ ។

**មាត្រា១៦ .-**

ការតម្លើងឋានន្តរសក្តិ ត្រូវប្រព្រឹត្តទៅតាមសំដាប់ថ្នាក់មួយសក្តិម្តង១ ហើយពុំអាចមានការតែងតាំងជាឋានន្តរសក្តិកិត្តិយសបានឡើយ ។ ក្នុងករណីមន្ត្រីនគរបាលជាតិកម្ពុជាណាម្នាក់បំពេញការងារមានស្នាដៃល្អពិសេសត្រូវបានតម្លើងឋានន្តរសក្តិមួយថ្នាក់ដោយពុំគិតពីលក្ខខ័ណ្ឌ និងអតីតភាពឡើយ ។

**មាត្រា១៧ .-**

ការតម្លើងឋានន្តរសក្តិរបស់មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវប្រព្រឹត្តទៅតាមលំដាប់នៃបញ្ជី អតីតភាព ។

ពុំអាចត្រូវតម្លើងឋានន្តរសក្តិបាន ក្នុងករណីពុំមានឈ្មោះនៅក្នុងតារាងតម្លើងឋានន្តរសក្តិ ដែលត្រូវរៀបចំឡើងក្នុងមួយឆ្នាំម្តងនោះទេ ។

ក្នុងករណីដែលមិនបានជាប់ឈ្មោះនៅក្នុងបញ្ជីតម្លើងឋានន្តរសក្តិប្រចាំឆ្នាំទេ មន្ត្រីនគរបាលជាតិកម្ពុជានោះ ត្រូវបានទទួលសិទ្ធិចុះឈ្មោះមុនគេបង្អស់ តាមលេខរៀងនៅក្នុងតារាងតម្លើងឋានន្តរសក្តិនាឆ្នាំបន្ទាប់ លើកលែងតែរដ្ឋមន្ត្រីក្រសួងមហាផ្ទៃសំរេចផ្ទុយពីនេះ ដោយមានសេចក្តីរាយការណ៍សមហេតុសមផល ពីមន្ត្រីដែលមានសមត្ថកិច្ច ។

**មាត្រា១៨ .-**

ការតែងតាំងឋានន្តរសក្តិ ត្រូវសំរេចដោយ :

-ព្រះរាជក្រឹត្យ សំរាប់ថ្នាក់ឧត្តមសេនីយ៍

-អនុក្រឹត្យ សំរាប់ថ្នាក់វរសេនីយ៍ឯក

-ប្រកាសរបស់ក្រសួងមហាផ្ទៃ សំរាប់ថ្នាក់វរសេនីយ៍ចុះ

## ជំពូកទី ៥

## សិទ្ធិ ភារកិច្ច និងភារកិច្ចទទួលខុសត្រូវ

**មាត្រា១៩ .-**

មន្ត្រីនគរបាលជាតិកម្ពុជាមានសិទ្ធិ និងសេរីភាពដូចប្រជាពលរដ្ឋដទៃទៀត ។ ក៏ប៉ុន្តែការប្រើសិទ្ធិនិងសេរីភាពខ្លះ ត្រូវមានកំរិតស្របតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ ។

**មាត្រា២០ .-**

មន្ត្រីនគរបាលជាតិកម្ពុជាត្រូវមានអព្យាក្រឹត្យភាពក្នុងមុខនាទី ក្នុងសកម្មភាពការងារ និងហាមឃាត់ការប្រើមុខងារ ការបំពេញភារកិច្ច និងប្រើប្រាស់មធ្យោបាយ សំភារៈរបស់រដ្ឋ ដើម្បីបំរើសកម្មភាព និងផលប្រយោជន៍គណបក្សនយោបាយណាមួយ ។

**មាត្រា២១ .-**

មន្ត្រីនគរបាលជាតិកម្ពុជាម្នាក់ៗ អាចមានគំនិត ឬជំនឿដែលមានលក្ខណៈជាទស្សនៈវិជ្ជា ឬនយោបាយផ្ទាល់ខ្លួនបាន ប៉ុន្តែពុំអាចសំដែងជាសាធារណៈបានឡើយ ។ វិធាននេះ មិនហាមឃាត់ដល់ការប្រតិបត្តិដោយសេរីនូវជំនឿសាសនា ក្នុងបរិវេណអង្គភាពរបស់កងកំលាំងនគរបាលជាតិកម្ពុជាឡើយ ។

**មាត្រា២២ .-**

មន្ត្រីនគរបាលជាតិកម្ពុជាដែលចង់បកស្រាយជាសាធារណៈ ជាអាទិ៍ ការសរសេរ ការធ្វើសន្និសីទ ឬសេចក្តីថ្លែងការណ៍នូវបញ្ហានយោបាយឬការសម្ងាត់របស់នគរបាលជាតិ ត្រូវបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា២៣ .-**

មន្ត្រីនគរបាលជាតិកម្ពុជាមានភារកិច្ចរក្សាការសម្ងាត់ជាតិ និងរក្សាការសម្ងាត់អំពីហេតុការណ៍ ពត៌មានដែលខ្លួនបានដឹងក្នុងពេលបំពេញភារកិច្ច ឬការសម្ងាត់ខាងវិជ្ជាជីវៈ ។ ការពង្វាង ឬការផ្តល់ពត៌មាន លិខិតស្នាម ឬឯកសារនៃសេវាផ្ទុយពីបទបញ្ជាទៅអោយតតិយជន ត្រូវហាមឃាត់ ។

**មាត្រា២៤ ._**

ការផ្សព្វផ្សាយក្នុងបរិវេណអង្គភាពរបស់នគរបាលជាតិកម្ពុជា ទោះជារូបភាពណាក៏ដោយដែលនាំអោយខូចដល់ទឹកចិត្ត ឬវិន័យ ត្រូវបានហាមឃាត់ទៅតាមល័ក្ខខ័ណ្ឌ ដែលមានចែងដោយ បទវិន័យរបស់នគរបាលជាតិកម្ពុជា ។

**មាត្រា២៥ ._**

មន្ត្រីនគរបាលជាតិកម្ពុជាអាចប្រមូលផ្តុំគ្នាបង្កើតជាក្រុមវិជ្ជាជីវៈ ដែលមានលក្ខណៈជាសមាគម ឬចូលរួមជាសមាជិកក្រុមវិជ្ជាជីវៈណាមួយ ដែលសមស្របទៅតាមបទវិន័យរបស់នគរបាលជាតិកម្ពុជា។

**មាត្រា២៦ ._**

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវទទួលបញ្ជាទៅបំរើការងារនៅគ្រប់កាលៈទេសៈ គ្រប់ពេលវេលា និងគ្រប់ទីកន្លែង ។ ប្រសិនបើការចាត់តាំងនោះបណ្តាលអោយជួបការលំបាក ដែលចាំបាច់ត្រូវការឧបត្ថម្ភ គ្រប់ថ្នាក់ដែលមានសមត្ថកិច្ច ត្រូវធានាផ្តល់អោយទៅតាមប្រភេទនៃការលំបាកនោះ ។

**មាត្រា២៧ ._**

មន្ត្រីនគរបាលជាតិកម្ពុជា អាចនឹងត្រូវបានផ្លាស់ប្តូរភារកិច្ច ទៅតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ ។

**មាត្រា២៨ ._**

មន្ត្រីនគរបាលជាតិកម្ពុជា មានសិទ្ធិសុំច្បាប់ឈប់សំរាកដោយមានប្រៀវត្ស រយៈពេលនិងបែបបទអនុញ្ញាតច្បាប់ត្រូវកំណត់ដោយបទវិន័យរបស់នគរបាលជាតិកម្ពុជា ។ ពេលចាំបាច់អាចកោះហៅជាបន្ទាន់នូវមន្ត្រីនគរបាលជាតិកម្ពុជា ដែលកំពុងឈប់សំរាកច្បាប់អោយចូលខ្លួនមកវិញ ។

**មាត្រា២៩ ._**

មន្ត្រីនគរបាលជាតិកម្ពុជាត្រូវគោរព និងអនុវត្តរាល់បញ្ជាដោយស្មារតីទទួលខុសត្រូវ ។ បញ្ជាណាដែលមានភាពច្បាស់ក្រឡែត ផ្ទុយពីច្បាប់ ឬផ្ទុយពីអនុសញ្ញាអន្តរជាតិ ត្រូវហាមឃាត់ ។ ក្នុងករណីនេះ អ្នកបញ្ជាក្តី ឬអ្នកអនុវត្តក្តី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

**មាត្រា៣០ ._**

មន្ត្រីនគរបាលជាតិកម្ពុជាទាំងអស់ត្រូវទទួលខុសត្រូវអំពីកំហុស និងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈព្រមទាំងបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងមុខងាររបស់ខ្លួន ។

ក្នុងករណីដែលមានពាក្យបណ្តឹងពីតតិយជនចំពោះមន្ត្រីនគរបាលជាតិកម្ពុជា ពីកំហុសក្នុង ការបំរើសេវាដែលមិនមែនជាកំហុសផ្ទាល់របស់មន្ត្រីនគរបាលជាតិកម្ពុជា រដ្ឋត្រូវការពារមន្ត្រីនគរបាលជាតិកម្ពុជារូបនោះចំពោះសំណងផ្នែករដ្ឋប្បវេណី ។

មន្ត្រីនគរបាលជាតិកម្ពុជាបំពេញភារកិច្ចដែលមានការគំរាមកំហែង ឬវាយប្រហារដោយប្រការណាមួយពីសំណាក់ជនណាម្នាក់ដែលមិនមែនជាកំហុសផ្ទាល់ខ្លួនត្រូវបានរដ្ឋការពារទទួលសងនូវការខូចខាត និងចេញមុខប្តឹងទៅតុលាការ ។

**មាត្រា៣១ ..**

មន្ត្រីនគរបាលជាតិកម្ពុជាត្រូវហាមឃាត់ជាដាច់ខាត :

១-យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត ។

២-យកឥទ្ធិពល និងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុតគំរាមកំហែងបំពានសិទ្ធិពលរដ្ឋ ។

៣-ប្រកបមុខរបរណាដែលនាំអោយប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់នគរបាលជាតិកម្ពុជា ។

៤-ចូលជាសមាជិកនៃក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល ។

ចំពោះមុខរបរណាដែលត្រូវបានអនុញ្ញាត និង មុខរបរណាដែលនាំអោយប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មន្ត្រីនគរបាលជាតិកម្ពុជា ហើយដែលត្រូវបានហាមឃាត់នោះ នឹងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៣២ ..**

មន្ត្រីនគរបាលជាតិកម្ពុជាត្រូវបានទទួលពិន្ទុមួយឆ្នាំម្តងសំរាប់ពិនិត្យតម្លើងថ្នាក់ ឬឋានន្តរសក្តិ ។ ប្រធានអង្គភាពផ្ទាល់ជាអ្នកដាក់ពិន្ទុ និងមូលវិចារណ៍ ។

**មាត្រា៣៣ ..**

មន្ត្រីនគរបាលជាតិកម្ពុជាណាដែលមានស្នាដៃ ត្រូវបានទទួលការលើកសរសើរជូនរង្វាន់តាមការកំណត់របស់ក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាល ។

## ជំពូកទី ៦
## ការចូលនិវត្តន៍

**មាត្រា៣៤ ._**

មន្ត្រីនគរបាលជាតិកម្ពុជាទាំងពីរភេទ ដែលបានបំរើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ហើយត្រូវបានដាក់អោយចូលនិវត្តន៍ :

ក-នៅពេលដល់អាយុ ៥៥ ឆ្នាំ ចំពោះមន្ត្រីនគរបាលជាតិកម្ពុជា ដែលមានឋានន្តរសក្តិថ្នាក់វរសេនីយ៍ចុះ ។

ខ-នៅពេលដល់អាយុ ៦០ ឆ្នាំ ចំពោះមន្ត្រីនគរបាលជាតិកម្ពុជា ដែលមានឋានន្តរសក្តិថ្នាក់វរសេនីយ៍ឯកឡើង ។

ការដាក់អោយចូលនិវត្តន៍ត្រូវសំរេចដោយ :

-ព្រះរាជក្រឹត្យ ចំពោះថ្នាក់ឧត្តមសេនីយ៍

-អនុក្រឹត្យ ចំពោះថ្នាក់វរសេនីយ៍ឯក

-ប្រកាសរបស់ក្រសួងមហាផ្ទៃ ចំពោះថ្នាក់វរសេនីយ៍ទោចុះ

**មាត្រា៣៥ ._**

របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងាររបស់មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៧
## ទណ្ឌកម្ម

**មាត្រា៣៦ ._**

មន្ត្រីនគរបាលជាតិកម្ពុជា ក្នុងករណីមានកំហុស ត្រូវទទួលទណ្ឌកម្មរបស់នគរបាលជាតិកម្ពុជាដូចខាងក្រោម ដោយមិនគិតពីការផ្តន្ទាទោសតាមផ្លូវតុលាការ ។

១-ទណ្ឌកម្មដែលកំណត់ដោយបទវិន័យរបស់នគរបាលជាតិកម្ពុជា ។

២-ទណ្ឌកម្មដែលកំណត់ក្នុងព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជាដែលមានចែងក្នុងមាត្រា ៣៩-៤០-៤១ និង ៤២ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា៣៧ .-**

មុននឹងដាក់ទណ្ឌកម្មតាមព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជាត្រូវសុំយោបល់ពីក្រុមប្រឹក្សាវិន័យជាមុន ។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាវិន័យ និងនីតិវិធីនៃការអនុវត្តន៍វិន័យចំពោះមន្ត្រីនគរបាលជាតិកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា៣៨ .-**

ក្រោយទទួលបានយោបល់ពីក្រុមប្រឹក្សាវិន័យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចសំរេចដាក់ទណ្ឌកម្មដែលមានចែងក្នុងមាត្រា ៣៩ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា៣៩ .-**

ទណ្ឌកម្មដែលត្រូវអនុវត្តចំពោះមន្ត្រីនគរបាលជាតិកម្ពុជាមាន :

-ការលុបឈ្មោះចេញពីតារាងតម្លើងឋានន្តរសក្តិ

-ការដកមុខដំណែងដោយអោយនៅក្នុងស្ថានភាពអសកម្ម

-ការដាក់អោយនៅទំនេរគ្មានបៀវត្ស មិនអោយលើសពីមួយឆ្នាំ

-ការបន្ថយឋានន្តរសក្តិ ឬថ្នាក់ មួយថ្នាក់ ឬច្រើនថ្នាក់

-ការដាក់អោយចូលនិវត្តន៍មុនកំណត់

-ការលុបឈ្មោះចេញពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

**មាត្រា៤០ .-**

ការដកមុខដំណែងដោយដាក់ក្នុងស្ថានភាពអសកម្ម ត្រូវអនុវត្តចំពោះតែមន្ត្រីនគរបាលជាតិកម្ពុជាណាដែលមិនមានសិទ្ធិចូលនិវត្តន៍ភ្លាម១ ។ ការដកមុខដំណែងមិនអាចមានរយៈពេលលើសពីមួយឆ្នាំឡើយ ។

នៅពេលផុតកំណត់នៃរយៈពេលដែលស្ថិតនៅក្នុងស្ថានភាពអសកម្ម មន្ត្រីនគរបាលជាតិកម្ពុជានោះ ត្រូវដាក់អោយនៅក្នុងស្ថានភាពសកម្មវិញ ។

រយៈពេលអសកម្មដោយការដកមុខដំណែង មិនត្រូវយកមកគិតក្នុងការតម្លើងឋានន្តរសក្តិទេ ។

**មាត្រា៤១ .-**

មន្ត្រីនគរបាលជាតិកម្ពុជាដែលត្រូវបន្ថយឋានន្តរសក្តិ ឬថ្នាក់ត្រូវបញ្ចូលទៅក្នុងឋានន្តរសក្តិថ្មី ឬថ្នាក់ថ្មីចាប់គិតពីថ្ងៃដែលមានការសំរេចជាផ្លូវការ ។

**មាត្រា៤២ ..**

ការលុបឈ្មោះមន្ត្រីនគរបាលជាតិកម្ពុជាចេញពីក្របខ័ណ្ឌ អនុវត្តបានដោយមិនគិតពីអតីតភាពការងារ ។

**មាត្រា៤៣ ..**

អនុក្រឹត្យ ឬប្រកាសដែលសំរេចចោទប្រកាន់ អំពីកំហុសខាងវិន័យនាំអោយមានការផ្អាកការងារមន្ត្រីនគរបាលជាតិកម្ពុជាជាបណ្តោះអាសន្ន តែមិនមានការបន្ថយបៀវត្សទេ ។

**មាត្រា៤៤ ..**

ការសំរេចផ្អាកការងារនៃមន្ត្រីនគរបាលជាតិកម្ពុជាជាបណ្តោះអាសន្ន មានកំណត់ត្រឹមចំនួន ៣ ខែ ប៉ុន្តែបើជាករណីពិសេស អាចសំរេចអោយបន្តជាថ្មីទៀតបានកំណត់ ១ ខែម្តង ប៉ុន្តែការបន្តនោះមិនត្រូវលើសពី ៣ ដងឡើយ ។

## ជំពូកទី ៨

## ការចោទប្រកាន់តាមផ្លូវតុលាការ

**មាត្រា៤៥ ..**

ក្នុងករណីដែលមន្ត្រីនគរបាលជាតិកម្ពុជាណាម្នាក់ ប្រព្រឹត្តបទល្មើសព្រហ្មទ័ណ្ឌ ហើយត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹង អំពីការចោទប្រកាន់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេល ៧២ ម៉ោងយ៉ាងយូរ ។

បើមានការចាប់ខ្លួន ឬការឃាត់ខ្លួន ឬការឃុំខ្លួនជាបណ្តោះអាសន្ន លើមន្ត្រីនគរបាលជាតិកម្ពុជាណាមួយនោះ ព្រះរាជអាជ្ញា ឬចៅក្រមមានសមត្ថកិច្ច ត្រូវរាយការណ៍ជាបន្ទាន់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា៤៦ ..**

មន្ត្រីនគរបាលជាតិកម្ពុជាណាដែលកំពុងជាប់ការចោទប្រកាន់ទៅតុលាការជំនុំជំរះអាចត្រូវផ្អាកពីមុខងារសិនក្នុងករណីចាំបាច់ ។

ក្នុងករណីដែលមន្ត្រីនគរបាលជាតិកម្ពុជា ត្រូវផ្អាកពីការងារដោយផ្អាកបៀវត្ស មន្ត្រីនគរបាលជាតិកម្ពុជានោះ ត្រូវបានទទួលអោយចូលធ្វើការវិញភ្លាម ដោយគិតពីអតីតភាព ឋានន្តរសក្តិ សោធននិវត្តន៍ និងទទួលបៀវត្សប្រតិសកម្មផង បើតុលាការប្រកាសអោយរួចខ្លួនជាស្ថាពរ ។

**មាត្រា៤៧ ._**

ការផ្តន្ទាទោសជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយឥតព្យួរទោស បណ្តាលអោយមានការលុបឈ្មោះចេញពីក្របខ័ណ្ឌនគរបាលជាតិដល់មន្ត្រីនគរបាលជាតិកម្ពុជានោះ គិតពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

មន្ត្រីនគរបាលជាតិកម្ពុជា ដែលគេវ៉ាសុំឧទ្ធរណ៍ត្រូវដាក់អោយនៅទំនេរគ្មានបៀវត្សជាបណ្តោះអាសន្នដោយស្វ័យប្រវត្តិ ។

**ជំពូកទី ៩**

**អវសានប្បញ្ញត្តិ**

**មាត្រា៤៨ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤៩ ._**

នាយករដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៥០ ._**

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**